21. ព្រះដ៏មានមហិទ្ធិឫទ្ធិ
សូមរំដោះជនភៀសខ្លួននៅមជ្ឈិមបូព៌ាទាំងអស់
ដែលជាប់ក្នុងទំនាក់ទំនងដែលពោពេញដោយការរំលោភបំពាន។
ផ្តល់ឱ្យពួកគេនូវក្តីសង្ឃឹម និងសេរីភាពដែលកើតចេញពីទ្រង់។
(ទំនុកតម្កើង ១១៨:៥)

22. ព្រះអម្ចាស់អើយ
សូមលើកទឹកចិត្តមេដឹកនាំដែលមានឥទ្ធិពលនៅក្នុងប្រទេសស៊ីរី
និងហ្សកដានី ឱ្យបញ្ឈប់អាជីវកម្មពេស្យាចារ។ ហើយជួយក្មេងស្រីជំទង់
ដែលជាប់គាំងឱ្យដឹងពីតម្លៃពិតរបស់ពួកគេក្នុងទ្រង់ផងដែរ។
(អេភេសូរ ៣:១៧-១៩)

23. បិតាអើយ សូមថែរក្សាសុខភាពរបស់ស្ត្រីស៊ូដង់ខាងត្បូង
និងផ្គត់ផ្គង់តម្រូវការផ្នែកវេជ្ជសាស្ត្ររបស់គ្រួសារពួកគេអំឡុងពេលដែល
មានវិបត្តិផងដែរ។
ហើយប្រទានអោយពួកគេមានលទ្ធភាពក្នុងការទទួលបានការថែទាំសុខ
ភាពកាន់តែប្រសើរឡើង។ (ទំនុកតម្កើង ១០៣:២-៣)

24. ព្រះវរបិតាអើយ
សូមបង្ហាញពីសេចក្តីស្រឡាញ់ដល់អ្នកម្តាយដែលនៅលីវក្នុងប្រទេសអា
រ៉ាប់ ថាទ្រង់ពិតជាស្រឡាញ់ពួកគេ ហើយទទួលយកពួកគេជានិច្ច។
សូមជួយឱ្យពួកគេរកឃើញតម្លៃ និងការលើកទឹកចិត្តនៅក្នុងទ្រង់។
(ម៉ាថាយ ១០:៣១)

25. ឱ ព្រះវរបិតាអើយ
សូមការពារមេដឹកនាំក្រុមជំនុំនៃមជ្ឈិមបូព៌ាទាំងអស់
ដែលស្ថិតនៅក្រោមសម្ពាធពីអាជ្ញាធរ។
សុំទ្រង់ជួយអ្នកដឹកនាំទាំងនោះអោយទទួលដឹងពីព្រះវត្តមានរបស់ទ្រង់
ជារៀងរាល់ថ្ងៃ និងធ្វើឱ្យតុលាការគ្រប់គ្រងដោយអនុគ្រោះផងដែរ។
(យ៉ូហាន ១៥:១៨)

26. ព្រះអម្ចាស់អើយ
សូមលួងលោមស្ត្រីប៉ាឡេស្ទីនដែលកំពុងបាត់បង់កូនរបស់ពួកគេដោយ
សារតែសង្គ្រាម។ សូមបង្ហាញពួកគេថាទ្រង់គឺជាព្រះអង្គសង្គ្រោះ
ដើម្បីអោយពួកគេអាចទទួលបាននូវសេចក្តីសុខសាន្ត
ដែលមាននៅក្នុងទ្រង់។ (យ៉ូហាន ១៦:៣៣)

27.
ក្រុមស្ត្រីនៅលីប៊ីគឺជាក្រុមមួយក្នុងចំណោមក្រុមទាំងអស់ដែលមានសមា
ជិកតិចជាងគេក្នុងចំណោមបណ្តាក្រុមនៅប្រទេសអារ៉ាប់។
ព្រះវរបិតាអើយ សូមផ្តល់ឱកាសអោយស្ត្រីទាំងនោះបានឮ
និងស្តាប់អំពីដំណឹងល្អនិងក្តីសង្ឃឹមរបស់ទ្រង់ផងដែរ។ (កូឡុស ៤:៣)

28.
ស្ត្រីនៅមជ្ឈិមបូព៌ាជាច្រើនត្រូវបានគ្រួសាររបស់ពួកគេកាត់កាលចោល
ដោយសារពួកគេបានទទួលជឿព្រះ។ ព្រះអង្គអើយ
សូមបំពេញដួងចិត្តរបស់ពួកគេដោយសេចក្តីស្រឡាញ់
និងសេចក្តីមេត្តាករុណារបស់ព្រះអង្គ។ (១យ៉ូហាន ៣:១)

29. ឱ ព្រះវរបិតាអើយ យើងសូមសរសើរតម្កើងទ្រង់
ចំពោះការច្រូតកាត់ដ៏សម្បូរបែបក្នុងចំណោមស្ត្រីម៉ារ៉ុក។
សូមដឹកនាំក្រុមរបស់យើងដែលត្រូវបានបញ្ជាក់ភាពជាអ្នកដឹកនាំហើយ
អោយពួកគេអាចបម្រើដល់ស្ត្រីទាំងននោះ
និងផ្តល់ការប្រកបបែបគ្រីស្ទបរិស័ទជាមួយស្ត្រីទាំងនោះផងដែរ។
(លូកា ១០:២)

30. ឱ ព្រះអម្ចាស់អើយ សូមប្រទានប្រាជ្ញា
និងផ្តល់គំនិតច្នៃប្រឌិតដល់ក្រុមសួរសុខទុខរបស់យើងនៅអារ៉ាប់
ក្នុងការដែលពួកគេធ្វើការដោះស្រាយបញ្ហាទាក់ទងនឹងការស្នើរសុំជាច្រើ
នសម្រាប់ជំនួយអាហារ និងហិរញ្ញវត្ថុផងដែរ។ (ម៉ាថាយ ៧:១១)

후원안내

국민은행 851-01-0003-724 북방선교방송

최초 입금 후 사무실로 연락 주시기 바랍니다

# Women of Hope
## Prayer Calendar

ប្រតិទិនអធិស្ឋានចេញផ្សាយជារៀងរាល់ខែ ដែលមានជាង
100ភាសា និងមានអ្នកចូលរួមអធិស្ឋានជាង 65,000នាក់



2022. 09.

## ការអធិស្ឋានសម្រាប់ស្ត្រីនៅអាស៊ីភាគកណ្តាល មជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង

ឥស្លាមមានន័យថា 'ការថ្វាយខ្លួន' ជាភាសាអារ៉ាប់
ហើយទាមទារឱ្យមានការចុះចូលពេញលេញចំពោះអល់ឡោះ។
វាក៏មានអត្ថន័យនៃ "សន្តិភាព"
ហើយវាត្រូវបានគេនិយាយថាសន្តិភាពពិតប្រាកដអាចទទួលបានតាមរយៈ
ការស្តាប់បង្គាប់អល់ឡោះ។ សូមចូលរួមអធិស្ឋានថា
គ្រិស្តបរិស័ទនឹងបន្តចែកចាយដំណឹងល្អអំពីព្រះយេស៊ូវតាមរយៈជីវិតរបស់
ពួកគេ ដើម្បីឱ្យមូស្លីមបានដឹងថា
ព្រះយេស៊ូវគឺជាព្រះអង្គសង្គ្រោះតែមួយគត់របស់យើង។

**TWR Korea 북방선교방송**

서울특별시 관악구 양녕로 15, 월드빌딩 6층

전화 (02)886-5671 / 이메일 phkorea@twrk.or.kr

**អធិស្ឋានសំរាប់...............**

1. ឱ ព្រះដ៏មានមហិទ្ធិឫទ្ធិ សូមប្រទាននូវការបំណងចិត្ត និងការតស៊ូដល់ក្រុមស្ត្រីនៃក្តីសង្ឃឹម នៅក្នុងប្រទេសអារ៉ាប៊ីសាអូឌីត ក្នុងការដែលពួកគេបន្តឈោងចាប់ស្ត្រីដទៃទៀតជាមួយនឹងព្រះបន្ទូលដែលពោរពេញដោយក្តីសង្ឃឹមរបស់ទ្រង់។ (២ថែស្សាឡូនិច ៣:១៣)

2. បិតាអើយ ដោយសារមានការឡើងថ្លៃទ្វេដងទៅលើការជួល និងអាហារបានធ្វើស្ត្រីនៅលីវដែលមានកូនមិនអាចបង់ថ្លៃសម្ភារៈចាំបាច់បានទេនៅប្រទេសមជ្ឈិមបូព៌ា។ ព្រះអម្ចាស់អើយ សូមទ្រង់ផ្គត់ផ្គង់ដល់ស្ត្រី និងកុមារទាំងនោះអោយពួកគេមានកន្លែងស្នាក់នៅត្រឹមត្រូវ និងអាហារបរិភោគគ្រប់គ្រាន់ផងដែរ។ (ភីលីព ៤:១៩)

3. បិតាអើយ កូនដឹងថាទ្រង់មានព្រះទ័យសោកសៅនៅពេលដែលស្ត្រី និងកុមារជនជាតិលីបង់ត្រូវទទួលរងការរំលោភបំពានពីសំណាក់មនុស្សប្រុសនៅក្នុងជីវិតរបស់ពួកគេ នៅពេលដែលកំពុងតែមានការខកចិត្តចំពោះស្ថានភាពសេដ្ឋកិច្ចសព្វថ្ងៃ សូមទ្រង់បានការពារពួកគេ។ (ទំនុកតម្កើង ៩:៩)

4. ព្រះបិតាអើយ សូមប្រទានសន្តិភាព និងប្រាជ្ញាដែលមកពីទ្រង់ដល់ស្ត្រីគ្រីស្ទាននៅប្រទេសអារ៉ាប៊ីសាអូឌីត ដែលកំពុងរស់នៅក្នុងសហគមន៍ដែលមានច្បាប់តឹងរ៉ឹង ដែលពួកគេមិនអាចប្រកាសអំពីជំនឿរបស់ពួកគេបាន។ (ទំនុកតម្កើង ១១៨:៦)

5. ព្រះអម្ចាស់អើយ សូមលើកទឹកចិត្ត និងបង្ហាញក្តីសង្ឃឹមរបស់ទ្រង់ចំពោះគ្រួសារនៅមជ្ឈិមបូព៌ាដែលត្រូវបាននិរទេសទៅក្នុងប្រទេសផ្សេងៗទៀត។ (ចោទិយកថា ១០:១៩)

6. បិតាអើយ សូមចូលទៅជិតស្ត្រីជនជាតិស៊ីរីដែលបានរស់នៅក្នុងជំរុំជនភៀសខ្លួនអស់រយៈពេល 11ឆ្នាំ សូមប្រើប្រាស់កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម ដើម្បីជួយពួកគេអោយបានស្វែងរកក្តីសង្ឃឹមដែលមាននៅក្នុងទ្រង់។ (រ៉ូម ១៥:១៣)

7. ព្រះជាម្ចាស់អើយ សូមប្រទានព្រះពរ និងផ្គត់ផ្គង់ដល់ស្ត្រីមេម៉ាយនៅមជ្ឈិមបូព៌ា ដែលទទួលបានប្រាក់កម្រៃតិចតួច និងមិនមានការជួយដោយគ្រួសាររបស់ពួកគេ។ សូមផ្តល់នូវអំណាចដែលពោរពេញដោយកម្លាំងដែលមកពីទ្រង់ដល់ស្ត្រីទាំងនេះ។ (អេសាយ ៤១:១០)

8. ឱ ព្រះវរបិតាដែលគង់នៅស្ថានសួគ៌អើយ សូមចម្រើនកម្លាំងដល់អ្នកជម្ងឺធ្ងន់ធ្ងរនៅមជ្ឈិមបូព៌ាដោយអំណាចព្រះចេស្តារបស់ទ្រង់ ហើយនាំមកនូវការព្យាបាលដល់ព្រលឹងវិញ្ញាណ និងរូបកាយពួកគេ ពីព្រោះពួកគេមិនអាចមានលទ្ធភាពក្នុងការបង់ទោះក្នុងតម្លៃអតិផរណា 300% នៃឱសថនោះទេ។ (យេរេមា ១៧:១៤)

9. ស្ត្រីប្រាំពាន់នាក់ត្រូវបានសម្លាប់ជារៀងរាល់ឆ្នាំនៅមជ្ឈិមបូព៌ា "ដើម្បីកិត្តិយស" ទោះបីជាពួកគេគឺជាជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទក៏ដោយ។ ព្រះអង្គអើយ សូមទ្រង់នាំមកនូវការផ្លាស់ប្តូរវប្បធម៌នៅក្នុងចិត្តរបស់ពួកគេ ដើម្បីអោយអំពើដ៏ឃោរឃៅនេះត្រូវបានបញ្ចប់។ (១ធីម៉ូថេ ២:១-២)


**Phum Roung Chak, Sangkat Kok Kleang,**

**Khan Sen Sok, Phnom Penh**

**(ភូមិរោងចក្រ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខរាជធានីភ្នំពេញ)**

**Tel: 092 60 60 51 /086 60 60 56**


10. ព្រះអម្ចាស់អើយ សូមពង្រឹងចំណងអាពាហ៍ពិពាហ៍គ្រីស្ទាននៅប្រទេសអារ៉ាប៊ីសាអូឌីត។ សូមលើកទឹកចិត្តបុរសឲ្យគេយុគនឹងសេចក្តីល្អ ហើយធ្វើជាអ្នកដឹកនាំដែលគោរពកោតខ្លាចដល់ព្រះទាំងក្នុងក្រុមគ្រួសារ និងព្រះវិហាររបស់ពួកគេផងដែរ។ (១ធីម៉ូថេ ៣:២-៥)

11. ព្រះអម្ចាស់អើយ សូមផ្តល់ភាពច្នៃប្រឌិតដល់ក្រុមព័ន្ធកិច្ចរបស់យើងដែលនៅអារ៉ាប់ ក្នុងការប្រើឧបករណ៍ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដើម្បីអោយបានទៅដល់ស្ត្រីដែលបាត់បង់ និងមានភាពឯកោ។ (ម៉ាកុស ១៦:១៥)

12. ឱ ព្រះដ៏មានមហិទ្ធិឫទ្ធិអើយ សូមទ្រង់ប្រទានព្រះពរ និងផ្គត់ផ្គង់ស្ត្រីជនបទនៅទុយនីស៊ីដែលប្រឈមមុខនឹងភាពអត់ការងារធ្វើ និងភាពក្រីក្រ។ សូមផ្តល់ប្រាជ្ញាដល់មន្ត្រីដែលមានឥទ្ធិពល ដើម្បីអោយពួកគេបានធ្វើការដោះស្រាយបញ្ហា និងស្វែងរកដំណោះស្រាយដែលមានប្រសិទ្ធភាពផងដែរ។ (ទំនុកតម្កើង ៦៨:១០)

13. ព្រះជាម្ចាស់អើយ សូមដឹកនាំស្ត្រីនៅមជ្ឈិមបូព៌ាដែលជាប់ពន្ធនាគា ដើម្បីអោយពួកគេបានស្វែងរកទ្រង់និងសេរីភាពពិតប្រាកដដែលមាននៅក្នុងទ្រង់ផងដែរ។សូមជួយពួកគេអោយរកអត្តសញ្ញាណពិតរបស់ពួកគេនៅក្នុងព្រះគ្រីស្ទ។ (យ៉ូហាន ៨:៣២)

14. ព្រះបិតាអើយ សូមបង្កើតទំនាក់ទំនងថ្មី និងស៊ីជម្រៅរវាងស្ត្រីមជ្ឈិមបូព៌ា និងទ្រង់។ អនុញ្ញាតឱ្យបុគ្គលិករបស់យើងមើលឃើញផលផ្លែនៃកិច្ចបម្រើរបស់ពួកគេ ហើយលើកទឹកចិត្តពួកគេដោយប្រាជ្ញា និងសេចក្តីមេត្តាករុណារបស់ទ្រង់ផងដែរ។ (កាឡាទី ៦:៩)

15. ព្រះអម្ចាស់អើយ សូមការពារ និងថែរក្សាផលផ្លែ និងធម្មជាតិថ្មីដែលបម្រើដល់គ្រួសារដែលត្រូវបាននិរទេសទៅក្នុងប្រទេសមជ្ឈិមបូព៌ា។ ជួយពួកគេឱ្យចែកចាយដំណឹងល្អអំពីទ្រង់ដែលប្រកបដោយប្រសិទ្ធភាព។ (លូកា ៩:៦)

16. ព្រះអើយ យើងអធិស្ឋានសម្រាប់ស្ត្រីនៃប្រទេសយេម៉ែន ដែលប្រឈមមុខនឹងអំពើហិង្សា ដោយសារជំនឿ និងវប្បធម៌មួយចំនួន។ សូមដឹកនាំអ្នកចូលរួមក្នុងក្រុមជំនុំសម្ងាត់នេះឱ្យប្រាប់អ្នកដទៃអំពីសេរីភាពដែលពួកគេបានរកឃើញនៅក្នុងព្រះគ្រីស្ទ។ (២កូរិនថូស ៣:១៧)

17. ព្រះវរបិតា អើយ សូមលើកបុរសនៅក្នុងប្រទេសអ៊ីរ៉ាក់ ឱ្យធ្វើជាអ្នកតស៊ូមតិដើម្បីសមភាពយេនឌ័រ។ សូមនាំមកនូវការផ្លាស់ប្តូរក្នុងការផ្តល់ការងារដោយយុត្តិធម៌ និងកាត់បន្ថយអំពើហិង្សាលើស្ត្រីផងដែរ។ (សុភាសិត ៣១:៨-៩)

18. យើងសូមអរព្រះគុណព្រះជាម្ចាស់ ដែលបន្ទាប់ពីមានការរឹតបន្តឹងជាច្រើន វេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម TWR ត្រូវបានចាប់ផ្តើមផ្សាយឡើងវិញនៅក្នុងប្រទេសអារ៉ាប៊ីសាអូឌីត។ សូមទ្រង់បន្តការពារពួកគេ។ (២ថែស្សាឡូនិច ៣:៣)

19. សូមអរព្រះគុណទ្រង់ ចំពោះស្ត្រីជនជាតិអាល់ហ្សេរី និងម៉ារ៉ុក ដែលបានឮអំពីព្រះបន្ទូលរបស់ទ្រង់ និងដឹងថាពួកពិតជាមានតម្លៃណាស់នៅក្នុងទ្រង់។ ព្រះបិតា អើយ សូមបង្កើនការចំណាប់អារម្មណ៍របស់ពួកគេ និងផ្លាស់ប្តូរជីវិតរបស់ពួកគេផងដែរ។ (ទំនុកតម្កើង ៦៣:១)

20. ឱ ព្រះវរបិតាអើយ សូមជួយបុគ្គលិក នៅTWRដែលបម្រើក្នុងព័ន្ធកិច្ចស្ត្រីក្នុងក្តីសង្ឃឹម នៅមជ្ឈិមបូព៌ា អោយបានធ្វើជាឯកអគ្គរដ្ឋទូតនៃទ្រង់ដ៏មានប្រសិទ្ធភាព ដើម្បីអោយពួកគេបានបញ្ជូនអត្ថន័យពិតនៃសេចក្តីស្រឡាញ់នៅក្នុងព្រះគ្រីស្ទដល់អ្នកដទៃ។ (រ៉ូម ៥:៨)